00867707

E253

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 12 / 2012
ម៉ោង (Time/Heure) : 15 : 25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

**សាធារណៈ / Public**

ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២
ការិយាល័យរដ្ឋបាល
ផ្នែកគ្រប់គ្រងតុលាការ

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង;
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** កាលបរិច្ឆេទដែលអង្គជំនុំជម្រះមិនធ្វើសវនាការក្នុងឆ្នាំ ២០១៣

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងផ្អាកមិនធ្វើសវនាការចាប់ពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ រហូតដល់ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣ នោះ អង្គជំនុំជម្រះសាលាដំបូងនឹងបន្តបើកសវនាការឡើងវិញនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣។ ដោយសារតែបញ្ហានៃការខ្វះខាតចំនួនបុគ្គលិកបំពេញការងារនៅបន្តនៅឡើយនោះ នៅពេលបន្តសវនាការឡើងវិញនាពេលខាងមុខ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការដោយផ្លាស់ពេលគ្នារវាងការធ្វើសវនាការចំនួនបួនថ្ងៃក្នុងមួយសប្តាហ៍ និងការធ្វើសវនាការចំនួនបីថ្ងៃក្នុងមួយសប្តាហ៍ ដោយត្រូវចាប់ផ្តើមធ្វើសវនាការរយៈពេលបួនថ្ងៃក្នុងអំឡុងសប្តាហ៍ នៃថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងដល់ភាគីអំពីកាលបរិច្ឆេទ មិនធ្វើសវនាការសម្រាប់ឆមាសទី ១ ក្នុងឆ្នាំ ២០១៣ ដូចខាង ក្រោមនេះ៖

ថ្ងៃ ច័ន្ទ ទី ២៥ ខែ កុម្ភៈ ដល់ ថ្ងៃ សុក្រ ទី ០១ ខែ មីនា ឆ្នាំ ២០១៣។

ថ្ងៃ ច័ន្ទ ទី ១៥ ដល់ ថ្ងៃ សុក្រ ទី ១៩ ខែ មេសា ឆ្នាំ ២០១៣។

ថ្ងៃ ច័ន្ទ ទី ១៣ ដល់ ថ្ងៃ សុក្រ ទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣។

អង្គជំនុំជម្រះសាលាដំបូងនឹងជូនដំណឹងអំពីកាលបរិច្ឆេទមិនធ្វើសវនាការផ្សេងទៀតនាពេលខាងមុខ។

នៅក្នុងអំឡុងពេលនៃកាលបរិច្ឆេទមិនធ្វើសវនាការដូចដែលបានបញ្ជាក់ខាងលើ ផ្នែកគ្រប់គ្រងតុលាការនឹងមិនទទួលយកឯកសារពាក់ព័ន្ធដាក់ចូលក្នុងសំណុំរឿង ០០២ ដែលស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។ ប៉ុន្តែពេលវេលាកំណត់សម្រាប់ការដាក់ឯកសារត្រូវគិតក្នុងអំឡុងពេលនៃកាលបរិច្ឆេទមិនធ្វើសវនាការខាងលើ។ ក្នុងករណីដែលកាលបរិច្ឆេទកំណត់ត្រូវចំនឹងថ្ងៃណាមួយក្នុងអំឡុងពេលខាងលើនេះ កាលបរិច្ឆេទសម្រាប់ការដាក់ឯកសារគឺ កំណត់យកថ្ងៃចូលធ្វើការដំបូងបន្ទាប់ពីកាលបរិច្ឆេទមិនធ្វើសវនាការ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ការអនុវត្តបែបនេះមិនប៉ះពាល់ដល់ការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះផ្សេងទៀតទេ ដោយរួមបញ្ចូលទាំងការដាក់បណ្ដឹងសាទុក្ខភ្លាមៗផងដែរ។

ថ្វីត្បិតតែកាលបរិច្ឆេទមិនធ្វើសវនាការខាងលើភាគច្រើនត្រូវនឹងថ្ងៃឈប់សម្រាកជាសាធារណៈរបស់ជាតិ និងអន្តរជាតិក្តី ក៏អង្គជំនុំជម្រះសាលាដំបូងនឹងពុំធ្វើសវនាការនៅថ្ងៃឈប់សម្រាកជាសាធារណៈដូច ដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប មួយចំនួនផ្សេងទៀត។ កាលបរិច្ឆេទនៃថ្ងៃឈប់សម្រាកបន្ថែមជាសាធារណៈរបស់ អ.វ.ត.ក នេះ ត្រូវបានការិយាល័យរដ្ឋបាលផ្ញើទៅភាគីនៅក្នុងសារាចររបស់ខ្លួនដែលមានចំណងជើងថា “ថ្ងៃបុណ្យឈប់សម្រាកជាផ្លូវការសម្រាប់ឆ្នាំ ២០១៣” ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ដែលភ្ជាប់មកជាមួយសម្រាប់ជាឯកសារយោងរួចហើយ។

អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា កាលបរិច្ឆេទមិនធ្វើសវនាការ មិនមែនជាថ្ងៃឈប់សម្រាកនោះទេ។ កាលបរិច្ឆេទទាំងនេះគ្រាន់តែជាថ្ងៃដែលអង្គជំនុំជម្រះមិនធ្វើសវនាការប៉ុណ្ណោះ។ ក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះសាលាដំបូងបំពេញការងារតុលាការផ្សេងៗទៀតរបស់ខ្លួន។